ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# ជម្រាបជូន
## ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឯកឧត្តមរដ្ឋមន្ត្រី ជាទីរាប់អាន!

ក្នុងឱកាសដែល **ឯកឧត្តមរដ្ឋមន្ត្រី** ត្រូវបានរដ្ឋសភាបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តឱ្យកាន់តំណែងជា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាសម័យប្រជុំ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ តាមសំណើដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមសំដែងនូវការអបអរសាទរយ៉ាងក្លៀវក្លា និងសូមជូនពរ **ឯកឧត្តមរដ្ឋមន្ត្រី** ទទួលបានជ័យជម្នះក្នុងភារកិច្ចបម្រើជាតិ និងប្រជាជនកម្ពុជាតាមរយៈការដឹកនាំ ជ្រោងស្ទួយវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ របស់ព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែមានការរីកចម្រើនទៅមុខគួរជាទីមោទនៈ ដើម្បីរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ និងប្រជាជនឱ្យកាន់តែខ្លាំងក្លាបន្ថែមទៀត។

ក្នុងឱកាសដ៏វិសេសវិសាលនេះ យើងខ្ញុំទាំងអស់គ្នាមានជំនឿយ៉ាងមុតមាំថា ក្នុងភាពជាអ្នកដឹកនាំវ័យក្មេងដែលទទួលបានការសិក្សាអប់រំខ្ពង់ខ្ពស់ ព្រមទាំងបទពិសោធន៍ការងារក្នុងរាជរដ្ឋាភិបាលអស់រយៈពេលជាច្រើនឆ្នាំមកនេះ **ឯកឧត្តមរដ្ឋមន្ត្រី** នឹងលើកតម្កើង ជំរុញវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ របស់ព្រះរាជាណាចក្រកម្ពុជា ឱ្យប្រែមុខមាត់ថ្មីឆ្ពោះទៅកាន់ភាពរីកចម្រើន និងទំនើបប្រកបដោយគុណផល អាចប្រកួតប្រជែងប្រកបដោយថាមភាពជាមួយប្រទេសក្នុងតំបន់ និងពិភពលោក។

ឆ្លៀតក្នុងវេលាប្រកបដោយមោទនភាពនេះ យើងខ្ញុំទាំងអស់គ្នាសូមជូនពរ **ឯកឧត្តមរដ្ឋមន្ត្រី ព្រមទាំងក្រុមគ្រួសារ** សូមមានសុខភាពល្អបរិបូរណ៍ និងសមប្រកបនឹងព្រះពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** ទទួលនូវការរាប់អានដោយស្មោះពីខ្ញុំ៕

ថ្ងៃ សុក្រ ៤ រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
រដ្ឋមន្ត្រី

ហ៊ុន សុខា

ផ្លូវវិថីអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh